ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍
# ភូមិកោះជ្រឹម
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះជ្រឹម |
| ភូមិ | ៖ | កោះជ្រឹម |
| ឃុំ | ៖ | អូរម្រះ |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែកុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ភូមិកោះជ្រឹម សម្រាប់រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះជ្រឹម |
| ភូមិ | ៖ | កោះជ្រឹម |
| ឃុំ | ៖ | អូរម្រះ |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែកុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះជ្រឹម
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះជ្រឹម |
| ភូមិ | ៖ | កោះជ្រឹម |
| ឃុំ | ៖ | អូរម្រះ |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែកុម្ភៈ ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ............ ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ............ ២
ក. ប្រជាពលរដ្ឋ ............ ២
ខ. មុខរបរ ............ ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ............ ៣
ក. ទីតាំង ............ ៣
ខ. ដែននេសាទ ............ ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ............ ៤
ឃ. ធនធានជលផល ............ ៤
៤. ការធ្វើនេសាទ ............ ៥
ក. អ្នកនេសាទ ............ ៥
ខ. ឧបករណ៍នេសាទ ............ ៥
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ............ ៦
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៦
ក.ទស្សនៈវិស័យ ............ ៦
ខ. គោលបំណងរួម ............ ៦
គ. គោលបំណងជាក់លាក់ ............ ៦
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៧
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ............ ៧
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ............ ៩
ឃ.៣. ការគ្រប់គ្រង ............ ១១
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............ ១៤
ច. យុទ្ធសាស្ត្រ ............ ១៤
ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិកោះជ្រឹមរយៈពេល ៣ ឆ្នាំ(កក្កដា២០១៩ មិថុនា ២០២២)............ ១៦
តារាងកម្មវិធីការងារប្រចាំឆ្នាំ កក្កដា ២០១៩-មិថុនា២០២២ ............ ២២

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិកោះជ្រឹម ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី១១ ឆ្នាំ២០០៦ ហើយបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១ សម្រាប់រយៈពេលបីឆ្នាំ គឺចាប់ពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលជាលើកទី២ គឺចាប់ពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨ ហើយត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលស្គាល់នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១១។ សហគមន៍នេសាទភូមិកោះជ្រឹមមានទីតាំងស្ថិតនៅក្នុងភូមិកោះជ្រឹម ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុប២២៥នាក់ ស្រីចំនួន១១៤នាក់ ស្មើនឹង១០០គ្រួសារ និងមានគណៈកម្មការចំនួន០៧ នាក់ ស្រីចំនួន០២នាក់។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទក៏អនុវត្តសកម្មភាពសំខាន់ៗ ដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ បច្ចុប្បន្នភាពសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ ការរៀបចំក្រុមល្បាត និងចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា។ រហូតមកដល់បច្ចុប្បន្នសហគមន៍នេសាទមានការរីកចម្រើន ដោយទទួលបានភាពជោគជ័យ ក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃលិចទឹក និងបានកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានា ដែលធ្វើឱ្យផលនេសាទមានការកើនឡើង។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទជួបប្រទះនូវបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ីរួមមាន ការធ្វើនេសាទខុសច្បាប់កើនឡើងជាពិសេសឆក់ប្រព្រឹត្តដោយអ្នកខាងក្នុង និងខាងក្រៅ នេសាទខុសច្បាប់នៅកន្លែងអន្លង់អភិរក្ស ខ្សត់ត្រី ធ្វើនេសាទ មិនសូវបានផល។

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានខ្វះដើមទុន ខ្វះមុខរបរចិញ្ចឹមជិវិត មានប្រាក់ចំណូលតិច ខ្វះបច្ចេកទេសចិញ្ចឹមសត្វ ខ្វះទីផ្សារ មណ្ឌលសុខភាពនៅឆ្ងាយហើយត្រូវឆ្លងទឹក ខ្វះធុងចម្រោះទឹកស្អាតគ្រួសារ ខ្វះបង្គន់អនាម័យ ផ្លូវក្នុងភូមិស្រុតដោយអន្លើ។

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានការសហការរួមមាន ជនល្មើសដដែលៗ ឃើញបទល្មើសមិនហ៊ានរាយការណ៍ សមត្ថភាពគណៈកម្មការនៅមានកម្រិត ប្រដេញទូកជលល្មើសមិនទាន់ ខ្វះការសហការក្នុងការចុះល្បាត ជនល្មើសដឹងពីផែនការចុះបង្ក្រាបជាមុន ប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មាការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចចិត្តនៅមានកម្រិត ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

ភូមិកោះជ្រឹមមានចំនួនប្រជាពលរដ្ឋសរុប៥១៩នាក់ ស្ត្រី២៦៤នាក់ ស្មើនឹង១០៤គ្រួសារ ក្នុងនោះមានជនជាតិខ្មែរចំនួន៨៧.២១% និងជនជាតិគួយចំនួន១២.៧៩% (៦៦នាក់ ស្ត្រី៣១នាក់)។ ប្រជាពលរដ្ឋជាអ្នកកាន់សាសនាព្រះពុទ្ធ មាន៩០% និងមានអ្នកកាន់សាសនាគ្រីស្តប្រមាណ១០% (៦០នាក់ ស្រី ៣៥នាក់)។ ប្រជាពលរដ្ឋមានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារមាន១៨នាក់
- ចំនួនស្ត្រីមេម៉ាយមាន១៦នាក់
- ចំនួនបុរសពោះម៉ាយមាន០៣នាក់
- ចំនួនជនពិការមាន ប្រុស០៣នាក់ ស្រី០១នាក់
- ចំនួនកុមារកំព្រាមាន០២នាក់
- ចំនួនចាស់ជរាមាន២៣នាក់ ស្រី១៨នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃមាន០១នាក់ ស្រី០១នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន៤០នាក់ ស្រី២០នាក់ បឋមសិក្សាចំនួនសរុប ៨២នាក់ ស្រី៣៦នាក់ អនុវិទ្យាល័យចំនួន២៦នាក់ ស្រី១៧ នាក់ វិទ្យាល័យចំនួន០១ នាក់(ស្រី០១នាក់។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន១០៤គ្រួសារ ត្រូវនឹង១០០%
- ធ្វើស្រែចំនួន១០៤ គ្រួសារ ដែលមានទំហំដីចំនួន៥៥ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន១៤ គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមានទំហំ១៥ម×១៥ម
- ជាងផ្ទះមានចំនួន០២គ្រួសារ
- ធ្វើចំការចំនួន៦០គ្រួសារ ទំហំដីចំការ១២០ហិកតា ដែលមានដំណាំចម្រុះដូចជាពោត សណ្តែក ល្ង ស្រូវ ដំឡូង ចន្ទី
- លក់ដូរជាអាជីព០១គ្រួសារ
- ប្រមូលទិញផលនេសាទ០៧គ្រួសារ
- ចិញ្ចឹមសត្វ១០៤គ្រួសារ
- ស៊ីឈ្នួល១០៣ នាក់
- ពេទ្យសត្វ០២ នាក់
- មន្ត្រីរាជការ០៨ នាក់ ស្រី០២នាក់។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិកោះជ្រីម ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិកោះជ្រីម មានទំហំ៤២៥ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់

- ខាងជើងទល់នឹងកន្ទុយកោះតាណាំ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងត្បូងទល់នឹងក្បាលកោះចង្កា កោះម្ទេស កោះថ្មគាបជាប់ព្រំប្រទល់សហគមន៍ភូមិកំពង់ក្បឿង ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងភូមិត្បូងខ្លា ឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹងកោះជ្រៃ ជាប់ព្រំប្រទល់សហគមន៍នេសាទភូមិអូរឡង់ ឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិកោះជ្រីមមានវិសាលភាពនៅក្នុងទន្លេមេគង្គ និងរួមទាំងមានអូរចំនួន០៤ កោះ ០៦ កោះ/កាំង និងអន្លង់អភិរក្សចំនួន០២។

ខ.១. ទន្លេ

| ឈ្មោះទន្លេ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៣.៥០០ | ពេញមួយឆ្នាំ |

ខ.២. អូរ

| ឈ្មោះអូរ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| អូរតាពុំ | ២០០ | កញ្ញា - តុលា |
| អូរម្កាក់ | ៣០០ | កញ្ញា - តុលា |
| អូរយាយហម | ១៥០ | កញ្ញា - តុលា |
| អូរសង្កែ | ១៥០ | កញ្ញា - តុលា |

ខ.៣ កោះ

| ឈ្មោះកោះ/កាំង | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ម៉ែត្រការេ) |
|---|---|---|
| កោះដំឡូង | ១០០ x ២០០ | ២០.០០០ |
| កាំងតាម៉ុម | ២០ x ៥០ | ១.០០០ |
| កាំងកូនសត្វ | ៥០ x ១០០ | ៥.០០០ |

| ឈ្មោះកោះ/កាំង | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ម៉ែត្រការេ) |
|---|---|---|
| កាំងធំ | ២៥០ x ៣០០ | ៧៥.០០០ |
| កោះជ្រៃ | ២០០ x ៣៥០០ | ៧០០.០០០ |
| កោះតាណាំ | ៣៥០ x ៤៥០ | ១៥៧.៥០០ |

ខ.៤ អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រការេ) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់ថ្មធំ | ៤០០ x ១៥០០ | ៦០០.០០០ | ៤០ | ៣០ |
| អន្លង់កោះដំឡូង | ៣០០ x ២៥០០ | ៧៥០.០០០ | ២៥ | ១៥ |

កន្លែងនេសាទសហគមន៍ភូមិកោះជ្រឹមមានព្រៃលិចទឹកទំហំសរុប១០ហិកតា ក្នុងនោះមានប្រភេទព្រៃដើមរាំង ដើមរៃ អញ្ចោង ដើមគ្រែង ដើមត្រស់ ដើមអញ្ចោ ដើមផ្ទា មានទំហំ០៥ហិកតា និងព្រៃលិចទឹកចំរុះទំហំ០៥ហិកតា។

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០២គឺអន្លង់ថ្មធំ និងអន្លង់កោះដំឡូង តាមការសម្រេចរបស់មហាសន្និបាត។

| ឈ្មោះ | ទទឹង និងបណ្តោយ (ម) | សរុប (ម៉ែត្រការេ) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា(ម) | រដូវប្រាំង(ម) |
| អន្លង់ថ្មតាព្រហ្ម | ៤០០ x ១៥០០ | ៦០០.០០០ | ៤០ | ៣០ |
| អន្លង់កោះដំឡូង | ៣០០ x ២៥០០ | ៧៥០.០០០ | ២៥ | ១៥ |

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេស ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីប៉ាសុីអុី ត្រីប៉ាវ៉ាមុខ១ ត្រីប៉ាវ៉ាមុខពីរ ត្រីប៉ាកក ត្រីគ្រំចិន ត្រីឆ្ពិន ត្រីកន្ធុប់ ត្រីក្របី ត្រីប្រម៉ា ត្រីត្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ទឹង ត្រីគល់រាំង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ទុង ត្រីឆ្ដោក ត្រីតានេល ត្រីអំបុង ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីបបែល ត្រីឫសចេក ត្រីស្លឹកចេក ត្រីចង្វា ត្រីថ្ម ត្រីដំរី ត្រីកំភ្លៀញ ត្រីផ្ទក់ ត្រីផ្កាត ត្រីអណ្តាតឆ្កែ ត្រីក្អុក ត្រីឆ្កៀត ត្រីកែ ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីកញ្ចុះប៉ាវ៉ា ត្រីស្លាបមាន់...។

ឃ.២. ប្រភេទវារីសត្វ៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់។

ឃ.៣. ប្រភេទបក្សី៖ ក្អែកទឹក កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ ទាទឹក ក្អែកគោក រំពេ ទុង ស្មោច កញ្ជិចពពេច សារិកាកែវ សេក លលក ពពូល ចាប ត្រចៀកកាំ រមាសអាច ក្លិត រំពេ ត្រយង រនាល ត្រដក់ ក្រសារ...។

ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ដើមរ៉ៃ ដើមអណ្ដែង ដើមជ្រៃ ដើមត្រែង ដើមល្ហាទឹក រាំងទឹក ដើមក្ដុល ព្រីងទឹក ដើមអញ្ចែង ផ្កា ត្រស់ អញ្ចែរ សណ្ដាន់ទឹក សណ្ដាន់គោក ញរទឹក ផ្ទុង ទន្លា កុល ក្របៅ ល្វា ស្ដី កាមល់ ស្វាយទឹក ជ្រយ ពោធ៌ ជ្រៃ ក្រឹម។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៩២គ្រួសារ ស្មើ២១៧នាក់ ស្រី១១២នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន៨៥ គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន២៥ គ្រួសារ។

ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក (គ្រួសារ) | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ៧០ x១= ៧០ | ១០x១= ១០ | ២០ x១= ២០ | សំរុង ៣.៥០ - ៥.៥០ម | សំរុង ៣.៥០ - ៥.៥០ម | សំរុង ៣.៥០ - ៥.៥០ម | ពេញមួយឆ្នាំ |
| សន្ទូចបង្កៃ | ផ្លែ | ៥០ x ១០០ = ៥០០០ | ៥ x ១០០= ៥០០ | ២០ x ១០០ = ២០០០ | ផ្លែលេខ ១៣-០៧ | ផ្លែលេខ ១៣-០៧ | ផ្លែលេខ ១៣-០៧ | មិថុនា -ធ្នូ |
| ចាន់ | គ្រឿង | ១០ x១០ =១០០ | ១០ x១០ =១០០ | | ០.៧ម x១ម | | | ពេញមួយឆ្នាំ |
| ជុច | គ្រឿង | ៥០ x៥២ =២០៨០ | | | មុខ៧ ស.ម ១.៥ ស.ម | | | ពេញមួយឆ្នាំ |
| លប | លប | ៣០ x២ = ៦០ | ១០ x២ = ២០ | | មុខ០.៣០ម បណ្ដោយ ១.៥០ម | មុខ០.៣០ ម បណ្ដោយ ១.៥០ម | | មិថុនា -ធ្នូ |

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន (ទូក) | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកចែវ | ៨ | ១០ | ០០ | ៥០-១០០ | ៥០-១០០ | ០០ | | | |
| ទូកមានម៉ាស៊ីន | ៦៥ | ៣០ | ៤០ | ១៥០-២៥០ | ១៥០-២៥០ | ២៥០-៤០០ | ៦-៨ | ៦-៨ | ១៣-១៨ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទ ភូមិកោះជ្រឹម មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកប ដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- បង្កើនធនធានជលផលតាមរយៈការបង្កើនការការពារអន្លង់អភិរក្សនិងកាត់បន្ថយការនេសាទខុសច្បាប់
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទតាមរយៈការបង្កើតមុខរបរ ផ្តល់ទុន និងបច្ចេកទេសកសិកម្ម ព្រមទាំងអនាម័យគ្រួសារ
- ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ និងបង្កើនការយល់ដឹងពីច្បាប់ដល់ប្រជាជន

គ. គោលបំណងជាក់លាក់

- ការពារតំបន់អភិរក្ស
- កាត់បន្ថយការនេសាទខុសច្បាប់
- ផ្តល់ទុនបង្កើត និងបង្កើនមុខរបរចិញ្ចឹមជីវិត
- បង្កើនអនាម័យក្នុងគ្រួសារ
- ពង្រឹងសមត្ថភាពគណៈកម្មការក្នុងការដឹកនាំ និងផ្តល់សម្ភារល្បាត
- បង្កើនកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ១- ក្នុងទន្លេមេគង្គ | នេសាទពេញមួយ | សំណាញ់ | ជម្រៅ០៤-០៥ម ក្រឡា០២-១០ស.ម | ១៧៥ | ៦០៩២ |



| | | | | | |
|---|---|---|---|---|---|
| | ឆ្នាំជា លក្ខណៈគ្រួសារ | សន្ទូច | លេខ១៤-៥ | ១០០ផ្លែ | =១២០ |
| | | លប | មុខកាត់០,៨០ម ប្រវែង១,៥០ម | ១០គ្រឿង | |
| | | ចាន់ | មុខកាត់០,៣០ម បណ្ដោយ០,៦ម | ១០គ្រឿង/គ្រួសារ | |
| | | ជុច | មុខកាត់៧ស.ម ប្រវែង១.៥ស.ម | ៤០គ្រឿង/គ្រួសារ | |
| ២- អូរ កោះ/កាំង | ខែ៧-ខែ១១ | សំណាញ់ | ជម្រៅ០៤-០៥ម ក្រឡា០២-១០ស.ម | ១វង់ | |
| | | សន្ទូច | លេខ១៤-៥ | ១០០ផ្លែ | |
| | | លប | មុខកាត់០,៨០ម ប្រវែង១,៥០ម | ១០គ្រឿង | |
| | | ចាន់ | មុខកាត់០,៣ម បណ្ដោយ០.៦ម | ១០គ្រឿង/គ្រួសារ | |
| | | ជុច | មុខកាត់៧ស.ម ប្រវែង១,៥ ស.ម | ៤០គ្រឿង/គ្រួសារ | |

ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ / ចំនួន | សកម្មភាព | ថវិកា (ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍ ភូមិកោះទ្រឹម ៤២៥ ហិកតា | បង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន ៥ បង្គោល | រៀបចំក្រុមបោះបង្គោល(ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់<br>• ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល<br>• ផ្សព្វផ្សាយជាសាធារណៈ | ២០០x៥ =១០០០ | គណៈកម្មការ សមាជិក មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |
| | លាបពណ៌ និងសរសេរអក្សរលើបង្គោលព្រំចាស់ | • រៀបចំក្រុមលាប ថ្នាំពណ៌<br>• ទិញថ្នាំពណ៌<br>• ចុះលាបថ្នាំពណ៌ តាមបង្គោល | ១២០ | | ៧/២០១៩ | ៦/២០២២ |

ឃ.១.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ (ហិចតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|

| ឈ្មោះ / ទីតាំង | ទំហំ (ហិចតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់ថ្មតាព្រហ្ម និងអន្លង់កោះដំឡូង | ៦២ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ស្លាកប៉ាណូតំបន់អភិរក្ស ១ផ្ទាំង<br>• ដាក់ស្លាកសញ្ញាហាមនេសាទកន្លែងអភិរក្ស ៥ផ្ទាំង<br>• ដាក់ពោងសំគាល់តំបន់អភិរក្ស៥ពោង | ៣០០<br>៥x១០០ =៥០០<br>៥x២៥ =១២៥ | ៧/២០១៩ | ៦/២០២២ |

ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ (ហិចតា) | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| តំបន់ព្រៃលិចទឹកក្នុងដែននេសាទសហគមន៍ភូមិកោះជ្រឹម | ១០ | ព្រៃលិចទឹកដែលត្រូវការពាររួមមានសណ្តាន់ រាំងតាអានទឹក ត្រី និងប្រភេទព្រៃចម្រុះ | .ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជា គណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>.ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក (៣៥ស្លាក)<br>.ចុះល្បាតជាប្រចាំ | ៣៥x៤ =១៥០ | ៧/២០១៩ | ៦/២០២២ |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន៥៥គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមមាន់តាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- ធ្វើទ្រុងនិងផ្តល់ពូជចិញ្ចឹម | ពូជក្នុងស្រុក | ៥៥x៣០០ =១៦.៥០០ | ៧/២០១៩ | ៦/២០២២ |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|
| | - តាមដានត្រួតពិនិត្យ | | | | |
| ចិញ្ចឹមទាយកពងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន១០គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមទាតាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- ធ្វើទ្រុងផ្តល់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ១០x៣០០ =៣.០០០ | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន០៥គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- ធ្វើទ្រុងនិងផ្តល់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ៥x៣០០ =១.៥០០ | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសលក្ខណៈគ្រួសារ ចំនួន១៥គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ១៥x៣០០ =៤.៥០០ | ៧/២០១៩ | ៦/២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសលក្ខណៈគ្រួសារ ចំនួន១៥ គ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ១៥x៣០០ =៤៥០០ | ៧/២០១៩ | ៦/២០២២ |
| ដាំបន្លែតាមបច្ចេកទេសលក្ខណៈគ្រួសារ ចំនួន១០គ្រួសារ | -ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ និងអនុវត្តផ្ទាល់<br>-ផ្តល់គ្រាប់ពូជបន្លែ<br>- ត្រួតពិនិត្យ និងតាមដាន | គ្រាប់បន្លែ (ប៉េងប៉ោះ ត្រកួន គ្រប់ ត្រសក់ ស្ពៃ) | ១០x៣០០ =៣.០០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជា | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | ៣៥គ្រួសារ (ស្រះទំហំ | ៣៥x៣០០ =១០.៥០០ | ១.០០០ក្បាលក្នុង១គ្រួសារ | ៧/២០១៩ | ៦/២០២២ |

| | | | | | | |
|---|---|---|---|---|---|---|
| លក្ខណៈគ្រួសារ ចំនួន៣៥គ្រួសារ | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>-ធ្វើអាងនិងដាក់កូនត្រី<br>-ត្រួតពិនិត្យតាមដាន | ២,៥មx៣ម) | | | | |

ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ប្រភេទមុខរបរ | សកម្មភាព | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ថ្មី ១ក្រុម (១ក្រុមមាន ៤០នាក់) | -ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>-ជ្រើសរើសអ្នកទទួលផល<br>-បោះឆ្នោតជ្រើសរើសមេដឹកនាំ<br>-បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនដល់ក្រុម<br>-ត្រួតពិនិត្យតាមដាន | ០ | ៧/២០១៩ | ៦/២០២២ |

ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវលំក្នុងភូមិ | ២០០០ ម | ១.៥០០ | ២០២០ | ២០២២ |
| ផ្តល់បង្គន់អនាម័យ | ៨០ បង្គន់ | ៨០x៧០០<br>=៥៦.០០០ | ២០២០ | ២០២២ |
| សាងសង់មណ្ឌលសុខភាព | ១ កន្លែង | ២៥.០០០ | ២០២០ | ២០២២ |
| ធុងចម្រោះទឹកតាមគ្រួសារ | ១០០ អាង | ១០០x២០<br>=២.០០០ | ២០២០ | ២០២២ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ១០-១៨ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/១ខែ | ៤.៥០០ | ៧/២០១៩ | ៦/២០២២ |
| ផ្តល់សម្ភារល្បាត១ឈុត | អាវពាង | ០៧ អាវ | ១.០០០ | ៧/២០១៩ | ៦/២០២២ |
| | អាវភ្លៀង | ០៧ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ០២ គោម | | | |
| | វិទ្យុទាក់ទង | ០២ គ្រឿង | | | |
| | កែវយឹត | ០២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ០១ គ្រឿង | | | |
| | អង្រឹង | ០៧ អង្រឹង | | | |
| | តង់គ្របទូក៥×៧ម | ២ តង់ | | | |
| | សម្ភារពិនិត្យទឹក | ០១ កំប្លេ | | | |
| | ស្លាបចក្រ | ០៦ គ្រឿង | | | |
| | សោរជួសជុលទូក | ០២ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ០២ សោរ | | | |
| | កេសដាក់សម្ភារ | ០២ កេះ | | | |
| | ក្តារព័ត៌មាន | ០១ ក្តារ | | | |
| | អាវយឺត មួក | ០៧ អាវ | | | |
| ទិញទូកស្នាច់ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | ៧/២០១៩ | ១២/២០១៩ |
| ប្រេងសម្រាប់ល្បាត | | ១០ លីត្រ/ខែ | | ៧/២០១៩ | ៦/២០២២ |
| សោជួសជុលថែទាំទូក និងម៉ាស៊ីន | | ២ ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| សាងសង់ស្នាក់ការសហគមន៍ | | ១ កន្លែង | ៣.០០០ | ៧/២០១៩ | ៦/២០២២ |

**ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ**

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ២-៣ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |
| ប្រជុំបណ្តាញសហគមន៍នេសាទ | ២ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |

| | | | | |
|---|---|---|---|---|
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការ | ១លើក/១ឆ្នាំ | ១៥០ | ៧/២០១៩ | ៦/២០២២ |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក/១ឆ្នាំ | ៤.៥០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ៣ដង/ឆ្នាំ | ១.០០០ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ២ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | ៤ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ៤ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល (តាមរយៈស្លាកសំខាន់ៗ) | ៦ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៦០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មាការ សហគមន៍នេសាទ | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មាការ សហគមន៍នេសាទ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព | ចុះប្រមូលប្រាក់សមាជិកភាព | ៧/២០១៩ | ៦/២០២២ | | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | ១៣៨ | |
| ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ | ៧/២០១៩ | ៦/២០២២ | ៦.៧៥០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | ៤.៥៩០ | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | ១១៨.០៨៧<br>(ចំណូលសរុប ១១.៤៧៨)<br>(ចំណាយសុប ១២៩.៥៦៥) | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងជនជាតិដើមភាគតិច | ៧/២០១៩ | ៦/២០២២ | គណៈកម្មការសហគមន៍នេសាទ | |

### ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមជិកសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងភាវីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ
- អញ្ជើញស្ត្រីមេគ្រួសារ និងស្ត្រីជនជាតិដើមភាគតិច ជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។



តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍តូមិកោះជ្រីរយៈពេល ៣ ឆ្នាំ (កក្កដា ២០២០ - មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ(រដូវបិទ និងបើកនេសាទ) | ១២០ (២x៦០) | អង្គការដៃគូ រដ្ឋបាលជលផល សហ.នេសាទ | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ ផ្លាំងប៉ាណូផែនទីសហគមន៍នេសាទ | បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន០៥ បង្គោល | ០៥បង្គោល | ១.០០០ (៥x២០០) | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | លាបពណ៌ និងសរសេរអក្សរលើបង្គោលព្រំចាស់ទាំងអស់ | បង្គោលព្រំចាស់ទាំងអស់ | ១២០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ប៉ាណូសំគាល់តំបន់អភិរក្ស | ចំនួន០១ផ្ទាំង | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | ដាក់ស្លាកសញ្ញាហាមនេសាទកន្លែងអភិរក្ស | ចំនួន៥ផ្ទាំង | ៥០០ (៥x១០០) | | ៧/២០១៩ | ៦/២០២២ | |
| | ដាក់ពោងសំគាល់តំបន់អភិរក្ស | ចំនួន៥ពោង | ១២៥ (៥x២៥) | | ៧/២០១៩ | ៦/២០២២ | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក | ចំនួន៣៥ស្លាក | ១៥០ (៣៥x៤) | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៥៥គ្រួសារ (៥០មាន់ក្នុង ០១គ្រួសារ) | ១៦.៥០០ (៥៥x៣០០) | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ចំណូល | ចិញ្ចឹមទាយកពងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ១០គ្រួសារ (៥០ទាក្នុង ០១គ្រួសារ) | ៣.០០០ (១០x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ១៥គ្រួសារ | ៤.៥០០ (១៥x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | ០៥គ្រួសារ (១០ក្បាលក្នុង ០១គ្រួសារ) | ១៥០០ (៥x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| | ចិញ្ចឹមក្របីតាមបច្ចេកទេសលក្ខណៈគ្រួសារ | ១៥ គ្រួសារ (១ក្បាល/គ្រួសារ) | ៤.៥០០ (១៥x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | ១០ គ្រួសារ | ៣.០០០ (១០x៣០០) | | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្ដែងក្នុងអាង (២,៥មx៣ម) តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៣៥ គ្រួសារ | ១០.៥០០ (៣៥x៣០០) | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើតក្រុមសន្សំប្រាក់ | ០១ក្រុម (១ក្រុមមាន ៤០ នាក់) | មិនចំណាយថវិកា | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | ៧/២០១៩ | ៦/២០២២ | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលផ្លូវលំក្នុងភូមិ | ២០០០ ម | ១.៥០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | ផ្ដល់បង្គន់អនាម័យ | ៨០ បង្គន់ | ៥៦.០០០ (៨០x៧០០) | | ៧/២០១៩ | ៦/២០២២ | |
| | ធុងចម្រោះទឹកតាមគ្រួសារ | ១០០ ធុង | ២.០០០ (១០០x២០) | | ៧/២០១៩ | ៦/២០២២ | |
| | សាងសង់មណ្ឌលសុខភាព | ១ ខ្នង | ២៥.០០០ | | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | ១០-១៨ដង/ខែ | | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ៤.៥០០ | | ៧/២០១៩ | ៦/២០២២ | |
| | ប្រេងសម្រាប់ល្បាត | ១៥០លីត្រ/១ខែ | | | | | |
| | សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | | | | | |
| | ផ្តល់សម្ភារល្បាត | ១ឈុត | ១.០០០ | | ៧/២០១៩ | ១២/២០១៩ | |
| | ទិញទូកស្ទាច់ម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ (២x១៥០០) | | ៧/២០១៩ | ១២/២០១៩ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ត្រូវបានសង់ | ៣.០០០ | | ៧/២០១៩ | ៦/២០២២ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ២ ទៅ ៣ដង/១ខែ | | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ សហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | | | ៧/២០១៩ | ៦/២០២២ | |
| | ប្រជុំបណ្តាញសហគមន៍នេសាទ | ២ដង/ឆ្នាំ | | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងទុកឯកសារ | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាព | ១លើក/១ឆ្នាំ | ១៥០ | | ៧/២០១៩ | ៦/២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក/១ឆ្នាំ | ៤.៥០០ | | ៧/២០១៩ | ៦/២០២២ | |
| យ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | បានផ្សព្វផ្សាយ២ដង/ឆ្នាំ | ១០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | បានផ្សព្វផ្សាយ២ដង/ឆ្នាំ | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | បានផ្សព្វផ្សាយ៤ដង/ឆ្នាំ | ២០០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | បានផ្សព្វផ្សាយ១ដង/ឆ្នាំ | ១០០ | | ៧/២០១៩ | ៦/២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | បានផ្សព្វផ្សាយ៤ដង/ឆ្នាំ | ២០០ | | ៧/២០១៩ | ៦/២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | បានផ្សព្វផ្សាយ២ដង/ឆ្នាំ | ៣០០ | | ៧/២០១៩ | ៦/២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ សមភាព សមធម៌យេនឌ័រ | បានផ្សព្វផ្សាយ១ដង/ឆ្នាំ | ៦០០ | | ៧/២០១៩ | ៦/២០២២ | |
| យ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ បុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | បានផ្សព្វផ្សាយ២ដង/ឆ្នាំ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលឃុំ | ៧/២០១៩ | ៦/២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់ឮសហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | មិនចំណាយថវិកា | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលឃុំ | ៧/២០១៩ | ៦/២០២២ | |
| យ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់ | ភាគទានសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | | សហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| អភិវឌ្ឍន៍សហគមន៍ | ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ ១ឆ្នាំម្តង | ១៣៨ | | ៧/២០១៩ | ៦/២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ | ៦.៧៥០ | | ៧/២០១៩ | ៦/២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | ៤.៥៩០ | | ៧/២០១៩ | ៦/២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ(ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយសប្បុរសជន) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | ១១៨.០៨៧ | | ៧/២០១៩ | ៦/២០២២ | |
| ង. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ត្រីមាស/ឆ្នាំ | មិនចំណាយថវិកា | អង្គការដៃគូ រដ្ឋបាលជលផល | ៧/២០១៩ | ៦/២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងជនជាតិដើមភាគតិច | ១ដង/ឆ្នាំ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ៧/២០១៩ | ៦/២០២២ | |

សម្គាល់៖ សហគមន៍នេសាទនៅខេត្តក្រចេះនិងស្ទឹងត្រែងដែលគម្រោងគាំទ្របានចាប់ផ្តើមរៀបចំផែនការគ្រប់គ្រង នៅត្រីមាសទី៤ ឆ្នាំ២០១៨។

# តារាងកម្មវិធីការងារប្រចាំឆ្នាំ កក្កដា ២០១៩- មិថុនា ២០២២

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| យ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| យ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | |
| យ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំធ្វើពីស៊ីម៉ងចំនួន០៥បង្គោល | | | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| លាបពណ៌ និងសរសេរអក្សរលើបង្គោលព្រំចាស់ទាំងអស់ | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| យ.១.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ប៉ាណូសំគាល់តំបន់អភិរក្ស | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាអភិរក្សចំនួន០៥ផ្ទាំង | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ពោងសំគាល់តំបន់អភិរក្ស៥ពោង | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | |
| យ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាចំនួន៣៥ | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ហាមកាប់ព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រី អណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់០១ក្រុម (១ក្រុមមាន ៤០នាក់) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវលំក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់បង្គន់អនាម័យ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ធុងចម្រោះទឹកតាមគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់មណ្ឌលសុខភាព | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.៣. ការគ្រប់គ្រង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្នាច់ម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សេវាជួសជុលថែទាំទូកនិងម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ស្នាក់ការសហគមន៍ | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ប្រជុំមហាសន្និបាតសហគមន៍នេសាទ | | | | X | | | | | X | | | | | | | X | | | | | | | X | | | | | X | | | | | | X | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងការរៀបចំទុកឯកសារ | | | | | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | | | | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការ | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | X | | | | | | | | | | | X | | | | | | | | | | | | | X | | | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ញត្តិក្នុងសហគមន៍នេសាទ | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងស.ហ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| ផ្សព្វផ្សាយផែននេសាទនិងការផ្ទៃក្នុងរបស់សហគមន៍ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |



tk

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ផ្សព្វផ្សាយច្បាប់ផលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ: បុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ប្រាក់បដិភាគមិនមែនជា | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ភាគទានប្រចាំឆ្នាំ | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ប្រាក់បដិភាគមិនមែនជាសមាជិកសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងជនជាតិដើមភាគតិច | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

លេខ : ០១៧/១៩....៥ម៉ស

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ចាឡាបរិវ៉ាត់,ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

ជ. នាយផ្នែករដ្ឋបាលជលផលចាឡាបរីវ៉ាត់

លេខ : ២ប២៧

បានឃើញ និងឯកភាព

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៩

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

អេង ជាសាន

លេខ : ២៣៦/១៩.........

បានឃើញ និងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលចាឡាបរីវ៉ាត់

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ឃុំអូរគ្រេះ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៩

មេឃុំអូរគ្រេះ

ចាន់ សុផល

លេខ : ២៧០.គរ២

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង_សេង

សូមគោរពជូន

លោកស្រីមេឃុំអូរគ្រេះ

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ភូមិកោះគ្រឹម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

ប្រធានគណៈកម្មការសហគមន៍នេសាទ

ភូមិកោះគ្រឹម

លេខ : ០៣៥/១៩....ខ.ជ.ស.ត

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

ទុំ នីរ៉ូ